**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**


<u>ប្រធានគណៈមេធាវី</u>

មេធាវី ប៊ុន ហុន

<u>ក្រុមប្រឹក្សាគណៈមេធាវី</u>

១-មេធាវី សាំង វណ្ណៈ

២-មេធាវី អ៊ុង គិរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៉ូលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកនួន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មានន្ទ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី យឹម វិស្សុត

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហួង

២៣-មេធាវី វ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ : ០៤៤ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យនៅក្រៅបញ្ជីគណៈមេធាវីបន្ត

### ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥

-បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០

-បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨

-យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨

-យោងតាមសេចក្តីសម្រេចលេខ ០៥៤/សសគម/១៤ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ របស់គណៈមេធាវី

-យោងតាមសំណើរបស់សាមីខ្លួន ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦។

## ស ម្រេ ច

**ប្រការ ១.-** អនុញ្ញាតឱ្យលោក **អ៊ុក វ៉ាប៊ុន** មេធាវីបានចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ **០៥៥** ស្ថិតនៅក្រៅបញ្ជីគណៈមេធាវីរយៈពេល ០២ឆ្នាំបន្តទៀត **ចាប់ពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៦** រហូតដល់**ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨** តាមសំណើសាមីខ្លួន។

**ប្រការ ២.-** ក្នុងរយៈពេលស្ថិតនៅក្រៅបញ្ជីនេះ លោក **អ៊ុក រ៉ាប៊ុន** ពុំអាចប្រកបវិជ្ជាជីវៈជាមេធាវី និងពុំអាចប្រើប្រាស់ឋានៈជាមេធាវី ប៉ុន្តែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី និងទទួលបាននូវឯកសារ-ព័ត៌មាននានាពីគណៈមេធាវី។

**ប្រការ ៣.-** លោក **អ៊ុក រ៉ាប៊ុន** ត្រូវមកដាក់ពាក្យសុំនៅក្រៅបញ្ជីជាបន្ត ឬ សុំចូលប្រកបវិជ្ជាជីវៈមេធាវីវិញ រយៈពេលយ៉ាងតិច ០២ (ពីរ) ខែ មុនដល់កាលបរិច្ឆេទផុតកំណត់ ដូចមានចែងក្នុងប្រការ ១ ខាងលើ។ ក្នុងករណីសាមីខ្លួនមិនបានមកដាក់ពាក្យទេ គណៈមេធាវីនឹងចាត់វិធានការតាមច្បាប់ជាធរមាន។

**ប្រការ ៤.-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន៕

**ចម្លងជូន :**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

*"ដើម្បីជូនជ្រាប"*

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ

មេធាវី.ប៊ុន-ហុន

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: 516
-ម៉ោង: 3-45
-ថ្ងៃ ខែ ឆ្នាំ: 11-3-16
-បញ្ជូន:

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខ្ញុំឈ្មោះ អ៊ុក វ៉ាប៊ុន មេធាវី អត្តលេខ ០៥៥**

## សូមជំរាបមក

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** ការដាក់នៅក្រៅបញ្ជីនៃគណៈមេធាវីរយៈពេល២ឆ្នាំ។
**យោង:** មាត្រា ៤០ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវីប្រកាសឱយប្រើដោយព្រះរាជក្រម លេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ១៩៩៥។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធានមេត្តាដាក់ឈ្មោះខ្ញុំឱយនៅក្រៅបញ្ជីនៃគណៈមេធាវីរយៈពេល២ឆ្នាំបន្តទៅទៀត ចាប់ពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាអនុញ្ញាតតាមការគួរ។

សូមលោកប្រធានមេត្តាទទួលនូវការគោរពរាប់អានពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០១៦

14/03/16

ប៊ុន ណាវីណា

**បណ្ឌិត អ៊ុក វ៉ាប៊ុន**

le 14-03-16

មេធាវី.ប៊ុន_ហុន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈមេធាវី**

❖❖❖❖❖❖❖❖❖

លេខ : 008

# បង្កាន់ដៃទទួលប្រាក់ពីការសុំនៅក្រៅបញ្ជី

បេឡាធិការគណៈមេធាវី បានទទួលពី លោក ~~លោកស្រី នាង~~កញ្ញា សិរ វ៉ាស៊ីប

ចំនួនទឹកប្រាក់ **USD** 120 ជាអក្សរ មួយរយម្ភៃ

រយៈពេល 2 ឆ្នាំ (ពីថ្ងៃទី 12 ខែ 3 ឆ្នាំ 2016 ដល់ថ្ងៃទី 12 ខែ 3 ឆ្នាំ 2018 ) ។

ភ្នំពេញ, ថ្ងៃទី ........ ខែ ........ ឆ្នាំ ........

បេឡាករ

RECEIVED
11 MAR 2016
BY: សេខ ផលរត្ន

បានឃើញ
ប្រធានគណៈមេធាវី

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

ប៊ុន ហុន

• យោងសេចក្ដីសម្រេច លេខ ០៩២/សសគម/០៨ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨